# បុព្វកថា

ព្រៃឈើមានចំណងទាក់ទងផ្ទាល់ជាមួយជីវិតនៅលើភពផែនដីនេះ។ បញ្ហាព្រៃឈើគឺជាបញ្ហាសកលសំរាប់ សង្គមមនុស្សទាំងមូល ។ ដូច្នេះក្នុងកិច្ចការពារវិស័យព្រៃឈើត្រូវមានការចូលរួមជាចាំបាច់ពីគ្រប់ភាគីទាំងអស់ ជាពិសេសសហគមន៍មូលដ្ឋាន ដែលជាកំលាំងចលករសំខាន់បំផុត និង មានឥទ្ធិពលដ៏ខ្លាំងក្លា។ សៀវភៅ "**បច្ចេកទេសដាំឈើសំរាប់កសិករ**" ដែលបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយបច្ចេកទេសដាំឈើ ដែលមានលក្ខណៈងាយស្រួលយល់សំរាប់ជំនួយឱ្យការងាររបស់អ្នកផ្សព្វ-ផ្សាយនៅមូលដ្ឋាន និង សំរាប់ការស្វែងយល់ពីបច្ចេកទេសរបស់អ្នកមានបំណងដាំឈើទាំងឡាយមានៈ កសិករ ផ្នែកឯកជន សាលារៀន វត្តអារាម កងកំលាំងប្រដាប់អាវុធ ។ល។ ការចងក្រងបានដកស្រង់យកបច្ចេកទេសពីឯកសារបច្ចេកទេសមួយចំនួនរបស់ជាតិ និង អន្តរជាតិ រួមផ្សំនឹងការផ្តល់ បទពិសោធន៍ល្អៗពីមន្ត្រីបច្ចេកទេសដែលមានបទពិសោធន៍ក្នុងការងារដាំឈើ និង សហគមន៍មកសំយោគបង្កើតជាបច្ចេកទេសមួយ ដែលមានលក្ខណៈសមស្របអាចអនុវត្តបាននៅក្នុងលក្ខខណ្ឌនៃប្រទេសកម្ពុជា។ ឯកសារនេះកសាង ឡើងក្រោមកិច្ចសហប្រតិបត្តិការជាមួយគំរោងវិស័យព្រៃឈើកម្ពុជា-អាល្លឺម៉ង់ (CGFP/GTZ) និង មានការចូលរួមគាំទ្រថវិកាពីគំរោងគ្រាប់ពូជកម្ពុជា (CTSP/DANIDA) គំរោងពង្រឹងសមត្ថភាពលើវិស័យព្រៃឈើ (CBFS/JICA) និង កម្មវិធីគាំទ្រផ្នែកកសិកម្មនៅកម្ពុជា (PRASAC II ) ប្រចាំខេត្តកំពង់ស្ពឺ។

ជាមួយការចូលរួមអនុវត្តដោយជោគជ័យតាមកម្មវិធីកំណែទំរង់វិស័យព្រៃឈើដ៏ទូលំទូលាយរបស់រាជរដ្ឋាភិបាលអណត្តិទី ២ ក្រោមការដឹកនាំដ៏ត្រឹមត្រូវ ម៉ឺងម៉ាត់ និង ឈ្លាសវៃបំផុតរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដោយបង្កើតបាននូវប្រក្រតីភាព និង សណ្តាប់ធ្នាប់ក្នុងវិស័យព្រៃឈើ ដែលអាចចាត់ទុកជាមូលដ្ឋានគ្រឹះសំរាប់ឈានឆ្ពោះទៅរកការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពនាពេលអនាគត។ ខ្ញុំសង្ឃឹមជឿជាក់ថា សៀវភៅ "**បច្ចេកទេសដាំឈើសំរាប់កសិករ**" នឹងក្លាយជាវិភាគទានដ៏មានតម្លៃសំរាប់ជំរុញលើកទឹកចិត្ត និង ផ្តល់ភាពងាយស្រួលដល់ពលរដ្ឋកម្ពុជា ដែលភាគច្រើនជាកសិករអាចចូលរួមយ៉ាងសកម្ម និង ប្រកបដោយប្រសិទ្ធភាពក្នុងសកម្មភាព វិស័យព្រៃឈើ ជាពិសេសការដាំដុះដើមឈើ ដើម្បីបង្កើនប្រភពចំណូល លើកកំពស់ការជីវភាព និង គុណភាពជីវិតរស់នៅ ក៏ដូចជួយបង្កើនគំរបធនធានព្រៃឈើសំរាប់ថែរក្សាលំនឹងបរិស្ថាន ដែលជាប្រពៃណីអភិរក្សដ៏ល្អរបស់ជាតិ សាសន៍កម្ពុជា។

**ទី.សុគន្ធ**

**ប្រធាននាយកដ្ឋានរុក្ខា.ប្រមាញ់**